ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

លេខៈ ០១ សកអ

ភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៦

# សារាចរណែនាំ
# ស្តីពី
# អតីតភាពការងាររបស់មន្ត្រីរាជការក្នុងការ
# ចូលនិវត្តន៍ និងចូលបាត់បង់សមត្ថភាពពលកម្ម

ក្នុងគោលបំណងចាត់តាំងអនុវត្ត គោលនយោបាយសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះមន្ត្រីរាជការស៊ីវិលអោយស្របតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល គោលនយោបាយរបស់រាជរដ្ឋាភិបាល និងដោយផ្អែកតាមស្មារតីនៃអង្គប្រជុំអន្តរក្រសួងថ្ងៃទី ១៤.១១.១៩៩៥ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនសូមណែនាំដូចខាងក្រោម ៖

ក. មន្ត្រីរាជកាដែលបានបម្រើការងាររដ្ឋ ទាំងក្នុង និងក្រៅប្រទេសមុនឆ្នាំ ១៩៧៩ ហើយបច្ចុប្បន្នកំពុងបម្រើការងាររដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានគិតបញ្ចូលក្នុងអតីតភាពការងាររយៈពេលបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃថែមទៀត នៅពេលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថភាពពលកម្ម។

ខ. មន្ត្រីរាជការដែលមានអាយុ ៥៥ឆ្នាំ ហើយនិងអតីតភាពការងារ ក្នុងចន្លោះរយៈពេលពី ២០ ឆ្នាំ ដល់ ក្រោម ៣០ ឆ្នាំ ត្រូវបានទទួលប្រាក់សោធននិវត្តន៍សមាមាត្រ។

គ. មន្ត្រីរាជការដែលមានអាយុ ៥៥ ឆ្នាំ បានបម្រើការងារ ៣០ ឆ្នាំយ៉ាងតិច ត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព។ ប៉ុន្តែមន្ត្រីរាជការ ដែលបានបម្រើការងាររយៈពេល ៣០ ឆ្នាំ អាចសុំចូលនិវត្តន៍មុនអាយុ ៥៥ ឆ្នាំបាន ដោយត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ហត្ថលេខា និងត្រា**

**ស៊ុយ សែម**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  “ ដើម្បីជូនជ្រាប ”
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជនខេត្ត -ក្រុង
  “ដើម្បីសហការអនុវត្ត ”
- កាលប្បវត្តិ - ឯកសារ